រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ឯកសារបច្ចេកទេស

# ស្តីពី

# ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង

# សម្រាប់រដ្ឋបាល ឃុំ សង្កាត់

លេខាធិការដ្ឋាន គ.ជ.អ.ប.

ខែកុម្ភៈ ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: ...០២៨...សសរ.../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី..១៧ ខែ...មីនា.... ឆ្នាំ២០១៧

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ឯកសារបច្ចេកទេសស្តីពី ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងសម្រាប់រដ្ឋបាលឃុំ សង្កាត់

## លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងព្រះរាជក្រមលេខ នស/រកម ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ មាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួននៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់នូវឯកសារបច្ចេកទេសស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង សម្រាប់រដ្ឋបាលឃុំ សង្កាត់" ។

**ប្រការ ២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងអ្នកពាក់ព័ន្ធមកពីវិស័យឯកជន និងសង្គមស៊ីវិលត្រូវរួមសហការគ្នាក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅតាមមូលដ្ឋានឃុំ សង្កាត់ ដោយអនុវត្តតាមបែបបទ នីតិវិធីនានាដូចបានកំណត់ក្នុងឯកសារបច្ចេកទេសនេះតាមតម្រូវការ និងស្ថានភាពជាក់ស្តែងរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ ។

**ប្រការ ៣.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានភារកិច្ចផ្តល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលឃុំ សង្កាត់ ដើម្បីឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗមានសមត្ថភាពគ្រប់គ្រាន់ក្នុងសម្របសម្រួល និងសហការជាមួយអ្នកពាក់នានាក្នុងការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅតាមមូលដ្ឋានឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព ។

**ប្រការ ៤.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**
**និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**សក់_សេដ្ឋា**

**<u>កន្លែងទទួល</u>**

- ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប (ដើម្បីជូនជ្រាប)
- ដូចប្រការ២ និង ប្រការ៣ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ ។

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ក្នុងគោលបំណងដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង តាមរយៈការអភិវឌ្ឍមូលដ្ឋាន និង ការផ្តល់សេវាសាធារណៈស្របនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដោយ ចាប់ផ្តើមពីការធ្វើកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់នៅឆ្នាំ២០០២ និង បន្តទៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ នៅឆ្នាំ២០០៨។

តួនាទីចម្បងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសរដ្ឋបាលឃុំ សង្កាត់ គឺត្រូវជានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយ សាធារណៈជូនប្រជាពលរដ្ឋ។ ការប្រើប្រាស់គ្រឿងស្រវឹង ត្រូវបានគេ ចាត់ទុកថា ជាមូលហេតុចម្បងមួយដែលបង្កឲ្យមានអសន្តិសុខដល់ សង្គម គ្រួសារ និងបុគ្គល។ តាមន័យនេះ ការបង្ការ និងការទប់ស្កាត់ ការប្រើប្រាស់គ្រឿងស្រវឹង គឺជាកិច្ចការមួយដែលរដ្ឋបាលឃុំ សង្កាត់ត្រូវ ចាត់វិធានការសមស្របនានា ដើម្បីធានាឲ្យប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ របស់ខ្លួនរស់នៅប្រកបដោយសុខុដុមរមនា។

ដើម្បីជួយឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ មានចំណេះដឹងជាមូលដ្ឋាន សម្រាប់អនុវត្តកិច្ចការនេះឲ្យមានប្រសិទ្ធភាព លេខាធិការដ្ឋាន គ.ជ.អ.ប ដោយសហការជាមួយអ្នកពាក់ព័ន្ធនានា បានរៀបចំ និងដាក់ឲ្យអនុវត្ត នូវឯកសារបច្ចេកទេសស្តីពី **"ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងសម្រាប់រដ្ឋបាលឃុំ សង្កាត់"**។ ជាមួយគ្នានេះ លេខាធិការដ្ឋាន គ.ជ.អ.ប សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះយោបល់តិទៀនស្ថាបនា ដើម្បី កែលម្អឯកសារបច្ចេកទេសនេះឲ្យកាន់តែមានលក្ខណៈល្អប្រសើរ។

## មាតិកា


អារម្ភកថា i

សេចក្ដីផ្ដើម ១


### ផ្នែកទី១
### និន្នាការទូទៅនៃការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង


១.១. និយមន័យ ៣

១.២. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ៥

១.៣. ប្រភេទគ្រឿងស្រវឹង ៨

១.៤. ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង ៩


### ផ្នែកទី២
### យន្តការ និងតួនាទីក្នុងការបង្ការ និងការទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង


២.១. រដ្ឋបាលឃុំ សង្កាត់ ១២

២.១.១. គ.ក.ន.ក ១៤

២.១.២. មណ្ឌលសុខភាព ១៥

២.១.៣. សាលារៀន ១៦

២.១.៤. ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ១៦

២.១.៥. វត្តអារាម ១៧

២.១.៦. សហគមន៍ ១៨

២.២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ ១៨

# ផ្នែកទី៣
# ដំណើរការអនុវត្តការបង្ការ និងការទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង

៣.១. ការរៀបចំ និងអនុម័តដីកា ២២
៣.២. ការអនុវត្តដីកា ៣០

# ផ្នែកទី៤
# ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

៤.១. នៅថ្នាក់ឃុំ សង្កាត់ ៣៥
៤.២. នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ៤២

# សេចក្តីផ្តើម

ឯកសារបច្ចេកទេសស្តីពី "**ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងសម្រាប់រដ្ឋបាលឃុំ សង្កាត់**" នេះ ត្រូវបានរៀបចំឡើងសម្រាប់ជួយរដ្ឋបាលឃុំ សង្កាត់នីមួយៗ ក្នុងការលើកកម្ពស់សណ្តាប់ធ្នាប់សាធារណៈ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន។

ឯកសារបច្ចេកទេសនេះ ត្រូវបានរៀបរៀងឡើងដោយបែងចែកជាបួនផ្នែកដូចខាងក្រោម ៖

- **ផ្នែកទី១** "ទិដ្ឋភាពទូទៅនៃការបង្ការ និងការទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង" ដែលបរិយាយអំពី ៖
  - និយមន័យ
  - ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ
  - ប្រភេទគ្រឿងស្រវឹង
  - ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង

- **ផ្នែកទី២** "យន្តការ និងតួនាទីក្នុងការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង" ដែលបរិយាយអំពី ៖
  - រដ្ឋបាលឃុំ សង្កាត់
  - គ.ក.ន.ក
  - មណ្ឌលសុខភាព
  - សាលារៀន

- ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- វត្តអារាម និង
- សហគមន៍។

- **ផ្នែកទី៣** "ដំណើរការអនុវត្តការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង" ដែលបរិយាយអំពី ៖
  - ការរៀបចំ និងអនុម័តដីកា
  - ការអនុវត្តដីកា
- **ផ្នែកទី៤** "ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ" មានបរិយាយអំពី ទម្រង់ស្រង់ព័ត៌មានពាក់ព័ន្ធ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃនៅថ្នាក់ឃុំ សង្កាត់ និងការវាយតម្លៃពីរដ្ឋបាលក្រុង ស្រុក ខណ្ឌផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ ឯកសារបច្ចេកទេសនេះពុំមែនជាក្របខ័ណ្ឌគតិយុត្តដែលតម្រូវឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមទាំងស្រុងនោះទេ។ ក្នុងន័យនេះ នៅពេលអនុវត្តជាក់ស្តែង ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើការបត់បែនតាមស្ថានភាព និងតម្រូវការជាក់ស្តែងនៃរដ្ឋបាលឃុំ សង្កាត់នីមួយៗ។

# ផ្នែកទី១
# និន្នាការទូទៅនៃការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង

## ១.១. និយមន័យ

- **គ្រឿងស្រវឹង** យោងតាមគេហទំព័រ

  http://www.drugfeeworld.org/drugfacts/alcohol.html

  គ្រឿងស្រវឹង គឺជាគ្រឿងញៀនមួយប្រភេទដែលផ្សំពីសារធាតុអាល់កុល។ ជាទូទៅ ទោះបីជាគ្រឿងស្រវឹងត្រូវបានគេចាត់ទុកថា ជាគ្រឿងញៀនដែលមានកម្រិតញៀនទាប ក៏ដោយ ក៏អ្នកសេពអាចនឹងស្រវឹងនៅពេលដែលបរិមាណសារធាតុអាល់កុល ដែលគេបានទទួលទានច្រើនជាងបរិមាណដែលខ្លួនគេម្នាក់ៗអាចទប់ទល់បាន។ បរិមាណអាល់កុល ហួសពីកម្រិតទាំងនោះនឹងបណ្ដាលឲ្យអ្នកទទួលទានរងផលប៉ះពាល់មួយចំនួនដូចជា ពុល មានអារម្មណ៍ពិបាកក្នុងខ្លួន ដើរទ្រេតទ្រោត និយាយមិនច្បាស់ និយាយខុស បាត់បង់សតិ ក្អួត វិលមុខ ឬអាចសន្លប់ ឬស្លាប់បាត់បង់ជីវិត និងជាពិសេសអាចប្រព្រឹត្តសកម្មភាពខុសច្បាប់ ដូចជា ការប្រព្រឹត្ត**អំពើហិង្សាលើដៃគូស្និទ្ធស្នាល ឬអំពើហិង្សាក្នុងគ្រួសារ**ជាដើម ប្រសិនបើបរិមាណអាល់កុល ក្នុងខ្លួនមានច្រើនខ្លាំងហួសពេក។

- **ការបំពានគ្រឿងស្រវឹង** គឺសំដៅទៅលើបែបបទនៃការប្រើប្រាស់គ្រឿងស្រវឹង ដែលជាញឹកញាប់បង្កជាការលំបាកដល់ស្ថានភាពសេដ្ឋកិច្ច សង្គម ស្ថានភាពផ្ទាល់ខ្លួន ហើយក៏អាចប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់វាផងដែរ។ យោងតាមគោលការណ៍ណែនាំក្នុងការប្រឹក្សាយោបល់របស់អង្គការចិត្តសង្គមអន្តរវប្បធម៌(TPO) និងមូលនិធិអាស៊ី(TAF) ឆ្នាំ ២០១៦ បុគ្គលបំពានគ្រឿងស្រវឹងមានរោគសញ្ញាពិសេសមួយចំនួនដូចខាងក្រោម ៖
  - ✓ ស្រេកឃ្លានដែលពិបាកនឹងទប់ចិត្តបានក្នុងការប្រើប្រាស់គ្រឿងស្រវឹង
  - ✓ ចំណាយពេលវេលាច្រើនទៅលើសកម្មភាពផឹកស៊ី ឬដើម្បីគ្រប់គ្រងអាការៈធ្វើទុក្ខដោយសារខ្វះជាតិអាល់-កុលក្នុងខ្លួន
  - ✓ ទទួលទានបានច្រើន ហើយមិនងាយស្រវឹង
  - ✓ បរាជ័យក្នុងការបំពេញកាតព្វកិច្ចសម្រាប់គ្រួសារ សង្គម ឬការងារ។
- **ការបង្ការ និងទប់ស្កាត់** គឺជាសកម្មភាពរារាំង ឬប្រុងប្រយ័ត្ន ឬការការពារអ្វីមួយ ឬសកម្មភាពណាមួយមិនឱ្យអនុវត្ត ឬមិនឲ្យកើតមានឡើងនាពេលអនាគត។ ឧទាហរណ៍ ៖ ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុករំដួល ស្រុកស្វាយជ្រុំ និងក្រុងស្វាយរៀងក្នុងខេត្តស្វាយរៀង និងស្រុកឆ្លូង និងស្រុកព្រែកប្រសព្វក្នុខេត្តក្រចេះ បាននឹងកំពុងចាត់វិធាន-

ការបង្ការ និងទប់ស្កាត់អំពើហិង្សា ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹងរួចមកហើយ។

## ១.២. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយនានា

ទន្ទឹមនឹងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការតាក់តែងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹងនាពេលបច្ចុប្បន្ន ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាធរមាននានាពាក់ព័ន្ធនឹងការបង្ការ និងទប់ស្កាត់គ្រឿងស្រវឹង មានដូចជា ៖

- **ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ៖** យោងតាមមាត្រា៤៣នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានតួនាទីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។ ការប្រើប្រាស់គ្រឿងស្រវឹងមិនត្រឹមត្រូវ គឺជាមូលហេតុចម្បងមួយ ដែលនាំឲ្យមានអសន្តិសុខសង្គម ដូចជា ការបង្កគ្រោះថ្នាក់ដល់សង្គម គ្រួសារ និងសាមីខ្លួន។ តាមន័យនេះ រដ្ឋបាលឃុំ សង្កាត់អាចចាត់វិធានការនានាដើម្បីបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់របស់ខ្លួន។
- **ច្បាប់ស្តីពីចរាចរផ្លូវគោក** បានចែងអំពីវិធានការផ្លូវច្បាប់ចំពោះអ្នកបើកបរដែលស្ថិតនៅក្នុងស្ថានភាពស្រវឹង ដូចជា ៖
  - មាត្រា៨ បានចែងថា "ហាមពិសាគ្រឿងស្រវឹងដែលបណ្តាលឲ្យមានជាតិអាល់កុលចាប់ពី ០,២៥ (សូន្យក្បៀសម្ភៃប្រាំ) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី

០,៥០ (សូន្យក្បៀសហាសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ"

- មាត្រា៦៦ បានចែងថា "មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ត្រូវឃាត់យានជំនិះមិនឲ្យធ្វើចរាចរណ៍ ឬឃាំងទុកយានជំនិះរយៈពេលមិនលើសពីបីថ្ងៃ ដើម្បីធ្វើការពិន័យ និងកែតម្រូវលក្ខណៈបច្ចេកទេសទៅតាមករណីដែលអ្នកបើកបរបានប្រព្រឹត្តល្មើស និងបទប្បញ្ញត្តិចរាចរណ៍ដូចខាងក្រោម ៖ (១)យានជំនិះដែលអ្នកបើកបរកំពុងស្ថិតនៅក្នុងភាពស្រវឹង ដោយមានអត្រាជាតិអាល់កុលចាប់ពី០,២៥ (សូន្យក្បៀសម្ភៃប្រាំ) ដល់០,៣៩ (សូន្យក្បៀសសាមសិបប្រាំបួន) ក្រាមក្នុងមួយលីត្រខ្យល់ ឬស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងញៀន"
- មាត្រា៧៦ ចែងថា "ជនណាបើកបរយានយន្តមិនព្រមបញ្ឈប់យានយន្ត តាមការបញ្ជារបស់មន្ត្រីនគរបាលចរាចរណ៍ ដើម្បីធ្វើតេស្តពិនិត្យជាតិអាល់កុល ឬសារធាតុញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០៦ (ប្រាំមួយ)ថ្ងៃទៅ០១(មួយ)ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែនរៀល) ទៅ ៨០០.០០០ (ប្រាំបីសែនរៀល)"
- មាត្រា៧៧ចែងថា "ជនណាបើកបរយានយន្តនៅពេលដែលខ្លួនស្ថិតនៅក្នុងភាពស្រវឹង ដោយមានជាតិអាល់-

កុលចាប់ពី០,៤០ (សូន្យក្បៀសសែសិប) មីលីក្រាម ក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ (សូន្យក្បៀស ប៉ែតសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦ (ប្រាំ មួយ)ខែ និងពិន័យជាប្រាក់ ៨០០.០០០ (ប្រាំបី សែន)រៀល ទៅ៤០០០.០០០(បួនលាន) រៀល"។

- **ក្រមព្រហ្មទណ្ឌ ៖**
  - មាត្រា២៩៧ ស្តីពី**បទល្មើសស្រវឹងជាក់ស្តែង** ចែងថា "បុគ្គលណាដែលស្ថិតនៅក្នុងសភាពស្រវឹងជាក់ស្តែង នៅលើផ្លូវសាធារណៈត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ៥.០០០(ប្រាំពាន់រៀល) ទៅ១០.០០០(មួយម៉ឺន រៀល)"។
  - មាត្រា៣៤៣ ចែងថា "អំពើញុះញង់អនីតិជនដោយ ផ្ទាល់ឲ្យបរិភោគជាប្រចាំ និងយ៉ាងច្រើននូវគ្រឿងស្រវឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី១.០០០.០០០(មួយ លាន)រៀល ទៅ៤.០០០.០០០ (បួនលាន)រៀល" ផងដែរ។

- **គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ៖** រាជរដ្ឋាភិបាល កម្ពុជា បានដាក់ចេញនូវគោលនយោបាយភូមិ ឃុំមាន សុវត្ថិភាព ដើម្បីលើកកម្ពស់ និងជំរុញចលនាការពារសន្តិ- សុខសណ្តាប់ធ្នាប់សាធារណៈនៅគ្រប់ពេល និងគ្រប់ច្រក

ល្មកនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ចំណុចទី២នៃលក្ខ-ណៈសម្បត្តិភូមិ ឃុំមានសុវត្ថិភាព គឺគ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដែលក្នុងនោះ គ្រឿងស្រវឹង គឺជាផ្នែកមួយ ដែលរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ក្នុងការបង្ការ និងទប់ស្កាត់ជាចាំបាច់ផងដែរ។ ជាមួយគ្នានេះ នៅក្នុងលក្ខណៈសម្បត្តិទី៣នៃភូមិ ឃុំមានសុវត្ថិភាព គឺគ្មានអំពើហិង្សាក្នុងគ្រួសារ ក៏ដូចជាក្នុងសង្គម ដែលតាមរយៈការសិក្សារបស់អង្គការមូលនិធិអាស៊ីឆ្នាំ២០១៦ ស្ត្រីកម្ពុជាដែលមានប្តី ឬដៃគូជាអ្នកប្រើប្រាស់គ្រឿងស្រវឹង មានហានិភ័យទទួលអំពើហិង្សាពីដៃគូស្និទ្ធស្នាល ក្នុងចន្លោះពី ១៥២% (របាយការណ៍ WHO ឆ្នាំ២០១៥) ទៅ ៣០០% (របាយការណ៍ CDHS ឆ្នាំ២០១៤) ខ្ពស់ជាងអ្នកដែលមានប្តី ឬដៃគូមិនប្រើប្រាស់គ្រឿងស្រវឹង។

## ១.៣. ប្រភេទគ្រឿងស្រវឹង និងខ្នាតនៃការពិសា

យោងតាមឯកសារគោលការណ៍ណែនាំ ក្នុងការប្រឹក្សាយោបល់របស់អង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO) និងមូលនិធិអាស៊ី (TAF) ឆ្នាំ២០១៦ ខ្នាតនៃការពិសាគ្រឿងស្រវឹងបានបញ្ជាក់ពីកម្រិតសារធាតុអាល់កុលដូចខាងក្រោម ៖

| ល.រ. | ប្រភេទនៃគ្រឿងស្រវឹង | ចំណុះ | ជាអាល់កុល | រង្វាល់ |
|---|---|---|---|---|
| ១ | ស្រាបៀរទឹកខ្មៅ | ២៨៥ ម.ល | ៤,៨% | ១ កំប៉ុង |
| ២ | ស្រាបៀរទឹកស | ៣៣០ ម.ល | ៣,៥% | ១ កំប៉ុង |

| ល.រ. | ប្រភេទនៃគ្រឿងស្រវឹង | ចំណុះ | ជាអាល់កុល | រង្វាល់ |
|---|---|---|---|---|
| ៣ | ស្រាទំពាំងបាយជូ | ១០០ ម.ល | ១២% | ១ កែវ |
| ៤ | ស្រាខ្លាំង (ឧ.whisky) | ៣០ ម.ល | ៤០% | ១ ពែង |
| ៥ | ស្រាស | ៥០ ម.ល | ២០% | ១ កូនកែវ |
| ៦ | ទឹកត្នោតជូរ | ៥០០ ម.ល | | ១/២បំពង់ |

## ១.៤. ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង

យោងតាមការសិក្សារបស់អង្គការមូលនិធិអាស៊ី ការទទួលទាន និងផលិតគ្រឿងស្រវឹងក្នុងប្រទេសកម្ពុជា កំពុងមាននិន្នាការកើនឡើងគួរឲ្យព្រួយបារម្ភ។ ជាក់ស្តែងរបាយការណ៍បានបង្ហាញថា ក្នុងចន្លោះឆ្នាំ២០០៣ ដល់ ២០០៥ ពលរដ្ឋកម្ពុជាអាយុចាប់ពី១៥ឆ្នាំឡើងទៅ បានទទួលទានគ្រឿងស្រវឹងជាមធ្យម៤,៦លីត្រ ក្នុងមួយឆ្នាំ ហើយ បានទទួលទានរហូតដល់៥,៥លីត្រ ក្នុងឆ្នាំ២០១០ (របាយការណ៍ WHO ឆ្នាំ២០១៤) និង៦,១លីត្រក្នុងឆ្នាំ២០១៤ (របាយការណ៍ IOGT-NTO ឆ្នាំ២០១៤)។

ទន្ទឹមនេះ ដោយយោងតាមតម្រូវការការផលិតគ្រឿងស្រវឹងជាលក្ខណៈពាណិជ្ជកម្ម និងការផលិតស្រាអង្ករ ឬស្រាស តាមផ្ទះ ក៏កំពុងកើនឡើងផងដែរ។

ការប្រើប្រាស់គ្រឿងស្រវឹងពិសេសការសេពច្រើនហួសប្រមាណនោះអាចនឹងបង្កបញ្ហាច្រើន ដូចជា ៖

- **ការបង្កបញ្ហាដល់សង្គម**
  - **គ្រោះថ្នាក់ចរាចរណ៍** នៅពេលអ្នកស្ថិតនៅក្នុងស្ថាន-

ភាពស្រវឹង ហើយបើកបរ នោះអាចនឹងបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍។ គ្រោះថ្នាក់ចរាចរណ៍អាចបង្កឲ្យមានរបួស ពិការភាព ឬអាចបាត់បង់ជីវិតខ្លួនឯង និងជីវិតអ្នកដទៃផងដែរ។ លើសពីនេះទៀត គ្រោះថ្នាក់ចរាចរណ៍នេះ បណ្តាលឲ្យខូចខាតទ្រព្យសម្បត្តិ ខាតបង់ពេលវេលា បាត់បង់ធនធានមនុស្ស និងថវិកាទៀតផង។ យោងតាមបទសម្ភាសន៍វាំងកាសែតភ្នំពេញប៉ុស្តិ៍ជាមួយ នាយកវិទ្យាស្ថានសុវត្ថិភាពផ្លូវថ្នល់ គ្រោះថ្នាក់ចរាចរណ៍ក្នុងរយៈពេល ០៦ខែ ដើមឆ្នាំ ២០១៦ កន្លងទៅថ្មីនេះមានរហូតដល់៩០% ដែលកើតឡើងពីកត្តាមនុស្ស ហើយក្នុងនោះការបើកបរក្នុងស្ថានភាពស្រវឹងជាកត្តាមួយដ៏សំខាន់។

- **ការបង្កឲ្យមានទំនាស់នៅក្នុងសង្គម** ដូចជា ការរំខាន ការឈ្លោះប្រកែកគ្នា ការជេរប្រមាថគ្នា ការវាយតប់ ការប្រើអំពើហិង្សា ឬកាប់សម្លាប់គ្នាជាដើម។
- **ការរំលោភសេពសន្ថវៈ**
- ។ល។

- **បង្កបញ្ហាដល់គ្រួសារ**
  - ការបង្ករអំពើហិង្សាក្នុងគ្រួសារ និង**<u>លើដៃគូស្និទ្ធិស្នាល</u>**
  - ការខាតបង់ថវិកា
  - ការខាតបង់ទ្រព្យសម្បត្តិ
  - ការខាតបង់ពេលវេលាសម្រាប់រកប្រាក់ចំណូល

- បាត់បង់ធនធានមនុស្សក្នុងគ្រួសារ
- ការផ្ដល់នូវគំរូមិនល្អដល់កូន ឬអ្នកជំនាន់ក្រោយ
- នាំឲ្យមានភាពក្រីក្រ
- កូនៗមិនមានស្មារតីល្អ រីករាយក្នុងការទៅសាលា ឬមានទំនាក់ទំនងជាមួយសង្គម ។ល។

- **បង្កបញ្ហាដល់បុគ្គលខ្លួនឯង**
  - ប៉ះពាល់សុខភាព យោងតាមគេហទំព័រ http://www.drugfeeworld.org/drugfacts/alcohol.html ) ការប្រើប្រាស់គ្រឿងស្រវឹង ផ្ដល់នូវផលប៉ះពាល់អវិជ្ជមានដល់អ្នកប្រើប្រាស់ទាំងរយៈពេលខ្លី និងវែង ៖
    - + រយៈពេលខ្លីដូចជា ក្អួត រាគ ឈឺពោះ វិលមុខ ឈឺក្បាល មានភាពមិនប្រក្រតីក្នុងខ្លួន បាត់បង់សតិស្មារតី និយាយមិនច្បាស់ និយាយខុស ពិបាកដកដង្ហើម បាត់បង់ការចងចាំ ដើរទ្រេតទ្រោត ឬដួល សន្លប់ ឬស្លាប់ជាដើម។
    - + រយៈពេលវែង ដូចជា អាចបង្កឲ្យមានជំងឺលើសឈាម ខូចមុខងារថ្លើម ខូចមុខងារតម្រងនោម ដំបៅក្រពះ ចិត្តវិកល មហារីក ខ្សោយសមត្ថភាពផ្លូវភេទ ខ្សោយសមត្ថភាពបន្តពូជ និងជំងឺរ៉ាំរ៉ៃជាច្រើនទៀត។
  - បាត់បង់កេរ្តិ៍ឈ្មោះ ឬមានការរើសអើងពីសហគមន៍
  - ។ល។

# ផ្នែកទី២
# យន្តការ និងតួនាទីក្នុងការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង

យន្តការចម្បងៗក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងដែលមាននៅថ្នាក់ឃុំ សង្កាត់ អាចមានដូចជា ៖

- រដ្ឋបាលឃុំ សង្កាត់
- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ(គ.ក.ន.ក)
- មណ្ឌលសុខភាព
- សាលារៀន
- ប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- វត្តអារាម
- សហគមន៍
- អ្នកលក់ អ្នកផលិត
- អ្នកពាក់ព័ន្ធផ្សេងទៀត។

## ២.១. រដ្ឋបាលឃុំ សង្កាត់

ការប្រើប្រាស់គ្រឿងស្រវឹង អាចបណ្ដាលឲ្យមានអសន្តិសុខ ការបង្កគ្រោះថ្នាក់នានាដល់សាមីខ្លួន គ្រួសារ និងសង្គម។ ដូច្នេះ ក្នុងការអនុវត្តតួនាទីបម្រើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់អាចចាត់វិធានការនានា ដោយសហការ និងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ ដើម្បីបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់របស់ខ្លួន។

ការដាក់ចេញនូវដីកាស្តីពី "ការបង្ការ និងទប់ស្កាត់អំពើហិង្សា

រួមទាំងគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងស្រវឹង" គឺជាវិធានការមួយក្នុងចំណោមវិធានការផ្សេងៗទៀត ដែលរដ្ឋបាលឃុំ សង្កាត់អាចធ្វើបាន។ ក្នុងការអនុវត្តវិធានការនេះ រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវពិនិត្យមើលអំពីតម្រូវការនៃការចេញដីកា ថាតើការប្រើ-ប្រាស់គ្រឿងស្រវឹងមានស្ថានភាពយ៉ាងដូចម្ដេច? តើឃុំ សង្កាត់ចាំបាច់ត្រូវចេញដីកាដែរឬទេ? ក្នុងករណីមានតម្រូវការនៃការដាក់ចេញជាដីកា ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវណែនាំដល់មេឃុំ ចៅសង្កាត់រៀបចំសេចក្ដីព្រាងដីកា ដោយអនុវត្តស្របតាមនីតិវិធីនៃការរៀបចំដីកា ដូចមានកំណត់ក្នុងសៀវភៅណែនាំស្ដីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ ២០០៥។

មធ្យោបាយចាំបាច់ដទៃទៀត ដែលរដ្ឋបាលឃុំ សង្កាត់អាចអនុវត្តបានមានដូចជា ៖

- រៀបចំគម្រោងស្ដីពីការណែនាំ និងផ្សព្វផ្សាយអំពីការបង្ការ ការទប់ស្កាត់ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង ដោយដាក់បញ្ចូលគម្រោងផ្សព្វផ្សាយនេះ ទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ខ្លួន។ ក្នុងការអនុវត្តគម្រោងនេះ មេឃុំ ចៅសង្កាត់អាចសម្របសម្រួល សហការជាមួយអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។
- រៀបចំ ឬចូលរួមរៀបចំបិទផ្ទាំងប៉ាណូ ឬផ្ទាំងរូបភាពផ្សព្វ-ផ្សាយអំពី ការទប់ស្កាត់ ឬផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង។

- ដាក់បញ្ចូលការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងជារបៀបវារៈប្រជុំប្រចាំខែរបស់ខ្លួន ដើម្បីតាមដានអំពីវឌ្ឍនភាពនៃការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងក្នុងមូលដ្ឋានរបស់ខ្លួន។
- ណែនាំសាលារៀន ប៉ុស្ដិ៍នគរបាលរដ្ឋបាល មណ្ឌលសុខភាព មេភូមិ គ.ក.ន.ក វត្តអារាម សហគមន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមជួយណែនាំ អប់រំផ្សព្វផ្សាយ និងចាត់វិធានការទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង ក្នុងដែនរដ្ឋបាលឃុំ សង្កាត់។
- ណែនាំដល់ប៉ុស្ដិ៍នគរបាលរដ្ឋបាល ដើម្បីចាត់វិធានការតឹងរ៉ឹងលើសកម្មភាពបទល្មើស ឬអំពើហិង្សានានា ដែលកើតមាននៅក្នុងឃុំ សង្កាត់ រួមទាំងបទល្មើសដែលកើតឡើងដោយសារការសេពគ្រឿងស្រវឹង។
- ចូលរួមសហការអនុវត្តចាត់វិធានការលើទីតាំងផលិត ចែកចាយ និងប្រើប្រាស់គ្រឿងស្រវឹងដែលខុសច្បាប់។
- ។ល។

ក្នុងការអនុវត្តកិច្ចការទាំងអស់ខាងលើ រដ្ឋបាលឃុំ សង្កាត់អាចប្រើប្រាស់ និងបែងចែកភារកិច្ចដល់យន្តការមួយចំនួន ដែលមានស្រាប់នៅមូលដ្ឋានរបស់ខ្លួន ដូចខាងក្រោម ៖

### ២.១.១. គ.ក.ន.ក

ក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង គ.ក.ន.ក ឃុំ សង្កាត់ អាច ៖

- អប់រំ ណែនាំដល់អ្នកប្រើប្រាស់គ្រឿងស្រវឹងឲ្យកាត់បន្ថយ ឬបញ្ឈប់ការប្រើប្រាស់
- លើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹងដល់ប្រជាពលរដ្ឋ
- កៀរគរបុរស និងក្មេងប្រុសឲ្យចូលរួមទប់ស្កាត់ការប្រើប្រាស់គឿងស្រវឹងតាមរយៈការផ្សព្វផ្សាយតាមវេទិកា វគ្គបណ្តុះ-បណ្តាល និងកិច្ចប្រជុំនានា
- រាយការណ៍ និងស្នើសុំអន្តរាគមន៍ជាបន្ទាន់ដើម្បីឆ្លើយតបចំពោះបញ្ហា ឬអំពើហិង្សានានា ដែលកើតមាននៅតាមសហគមន៍ ដោយសារការសេពគ្រឿងស្រវឹង។ល។

## ២.១.២. មណ្ឌលសុខភាព

ក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង មណ្ឌលសុខភាពអាច ៖

- អប់រំ ណែនាំដល់អ្នកមកទទួលសេវាសុខភាពអំពីផលប៉ះពាល់ដល់សុខភាពនៃការប្រើប្រាស់គ្រឿងស្រវឹង និងវិធីសាស្ត្រកាត់បន្ថយ ឬបញ្ឈប់ការប្រើប្រាស់គ្រឿងស្រវឹង
- ចូលរួមសកម្មភាពផ្សព្វផ្សាយអំពីការលើកកម្ពស់សុខភាពសាធារណៈទាក់ទងនឹងការមិនប្រើប្រាស់គ្រឿងស្រវឹង
- រាយការណ៍ និងធ្វើបច្ចុប្បន្នភាពអំពីវឌ្ឍនភាពនៃចំនួនអ្នកជំងឺ និងជនរងគ្រោះបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹងដែលមកទទួលសេវាសុខភាព ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន

- ផ្តល់ការប្រឹក្សាយោបល់ដល់បុគ្គលបំពានគ្រឿងស្រវឹង ក្នុងករណីដែលទទួលបានការបណ្តុះបណ្តាល ជំនាញប្រឹក្សាយោបល់ត្រឹមត្រូវ។ល។

### ២.១.៣. សាលារៀន

ក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង សាលារៀន អាច ៖

- អប់រំ ណែនាំដល់សិស្សានុសិស្សអំពីការបង្ការ ការទប់ស្កាត់ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង
- ណែនាំសិស្សានុសិស្សកុំឲ្យប្រើប្រាស់គ្រឿងស្រវឹងទាំងនៅក្នុងសាលារៀន និងនៅក្រៅសាលារៀន
- លើកទឹកចិត្តសិស្សានុសិស្សឲ្យនិយាយថា "**ទេ**" ចំពោះគ្រឿងស្រវឹងគ្រប់ប្រភេទ
- លើកទឹកចិត្តឲ្យសិស្សានុសិស្សផ្សព្វផ្សាយបន្តអំពីការបង្ការ ការទប់ស្កាត់ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង ដល់គ្រួសារ សាច់ញាតិ មិត្តភក្តិ និងសហគមន៍របស់ខ្លួន ។ល។

### ២.១.៤. ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់

ក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អាច ៖

- ផ្តល់កិច្ចអន្តរាគមន៍បន្ទាន់ចំពោះបញ្ហា ឬសកម្មភាពអំពើហិង្សានានា ដែលកើតមាននៅតាមសហគមន៍ ដោយសារការសេពគ្រឿងស្រវឹង

- អប់រំ និងណែនាំដល់អ្នកប្រើប្រាស់គ្រឿងស្រវឹងឲ្យកាត់បន្ថយ ឬបញ្ឈប់ការប្រើប្រាស់
- លើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ និងច្បាប់ពាក់-ព័ន្ធ នៃការប្រើប្រាស់គ្រឿងស្រវឹងដល់ប្រជាពលរដ្ឋ
- រាយការណ៍អំពីស្ថានភាពនៃសកម្មភាព ឬបទល្មើស ឬអំពើហិង្សានានា ដែលកើតមាននៅក្នុងឃុំ សង្កាត់ រួមទាំងបទល្មើសដែលកើតឡើង ដោយសារការសេពគ្រឿងស្រវឹងជូនកិច្ចប្រជុំ គ.ក.ន.ក និងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់
- ។ល។

## ២.១.៥. វត្តអារាម

ព្រះសង្ឃ អាចារ្យវត្ត និងចាស់ព្រឹទ្ធាចារ្យ អាចដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមផ្សព្វផ្សាយអំពីការបង្ការ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង ដោយផ្អែកលើខ្លឹមសារនៃព្រះពុទ្ធសាសនា។

ជាក់ស្តែង សិក្ខាបទទី៥នៃសីលប្រាំក្នុងទ្រឹស្តីព្រះពុទ្ធសាសនាបានចែងថា "សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ" ដែលមានន័យថា ការមិនសេពនូវទឹកស្រវឹង ឬគ្រឿងដែលធ្វើឲ្យប្រាជ្ញាថយចុះ។ ជាទូទៅ មនុស្សលោក គឺជាប្រភេទសត្វលោកដ៏វិសេស និងប្រសើរខ្ពង់ខ្ពស់ជាងសត្វតិរច្ឆាន។ ការប្រើប្រាស់គ្រឿងស្រវឹងអាចធ្វើឲ្យមនុស្សលោកបាត់បង់នូវសតិសម្បជញ្ញៈ ហ៊ានប្រព្រឹត្តនូវអំពើគ្រប់បែបយ៉ាង មានអំពើអមនុស្សធម៌ ដូចជាសត្វតិរច្ឆានជាដើមផងដែរ។ តាមន័យនេះ ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ អាចារ្យ និង

អ្នកផ្សព្វផ្សាយព្រះពុទ្ធសាសនា អាចប្រើប្រាស់ខ្លឹមសារនៃព្រះធម៌ ដើម្បីអប់រំ ណែនាំ និងតម្រង់ទិសដល់ពុទ្ធសាសនិកទាំងអស់ឲ្យចូលរួមបង្ការ ទប់ស្កាត់ និងបញ្ឈប់ការប្រើប្រាស់គ្រឿងស្រវឹងនៅតាមសហគមន៍របស់ខ្លួន។

### ២.១.៦. សហគមន៍

ក្រៅពីយន្តការនានាខាងលើ សហគមន៍ និងបុគ្គលម្នាក់ៗនៅក្នុងសហគមន៍ គឺជាតួអង្គសំខាន់បំផុតក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង។ ការតាំងចិត្តក្នុងការបញ្ឈប់ ការប្រើប្រាស់គ្រឿងស្រវឹងរបស់បុគ្គលម្នាក់ៗ គឺជាចំណុចគន្លឹះសំខាន់ក្នុងការឈានទៅបញ្ឈប់សកម្មភាពប្រើប្រាស់គ្រឿងស្រវឹងក្នុងសហគមន៍ និងសង្គមទាំងមូល។ ជាការពិត ទោះបីជា បុគ្គល ឬសហគមន៍ទាំងមូលមិនអាចលប់បំបាត់ការប្រើប្រាស់គ្រឿងស្រវឹងទាំងស្រុងក៏ដោយ ក៏ការកាត់បន្ថយការប្រើប្រាស់ ឬការកំណត់អំពីកម្រិតនៃការប្រើប្រាស់ (មិនឲ្យហួសពីកម្រិត ឬបរិមាណដែលច្បាប់ចរាចរណ៍ផ្លូវគោកបានកំណត់) គឺជាមធ្យោបាយមួយ ដែលនឹងចូលរួមកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមានពីការប្រើប្រាស់គ្រឿងស្រវឹងផងដែរ។

## ២.២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យឃើញថា ស្ថានភាពនៃការប្រើប្រាស់គ្រឿងស្រវឹងកើតមានឡើងយ៉ាងច្រើននៅតាមឃុំ សង្កាត់នានាក្នុងក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់អាចស្នើសុំមកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដើម្បីចេញដីកា ដើម្បីបង្ការ និង

ទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងក្នុងក្រុង ស្រុក ខណ្ឌនោះ។ ក្នុងការរៀបចំដីការបស់ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវណែនាំអភិបាលក្រុង ស្រុក ខណ្ឌរបស់ខ្លួនឲ្យសិក្សាអំពីតម្រូវការនៃការដាក់ចេញដីកានោះ។ ក្នុងករណីដែលការសិក្សាបង្ហាញថា មិនមានតម្រូវការចេញដីកាសម្រាប់ក្រុង ស្រុក ខណ្ឌទាំងមូលទេ អភិ-បាលក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន និងត្រូវជូនដំណឹងទៅរដ្ឋបាលឃុំ សង្កាត់ដែលបានស្នើសុំ ដើម្បីឲ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗនោះនៅរៀបចំដីការបស់ខ្លួនរៀងៗខ្លួន។ ប៉ុន្តែ ប្រសិនបើការសិក្សាបង្ហាញថា ពិតជាមានតម្រូវការក្នុងការដាក់ចេញដីកា អភិបាលត្រូវរាយការណ៍ជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេចអំពីតម្រូវការដាក់ចេញដីកានោះ។ ក្រុមប្រឹក្សាត្រូវណែនាំឲ្យអភិបាលចាត់ចែងរៀបចំសេចក្តីព្រាងដីកា ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ ការរៀបចំសេចក្តីព្រាងនេះ ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ២៨៦/អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀប-ចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុម-ប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផលិតដោយក្រសួងមហាផ្ទៃក្នុងឆ្នាំ២០១៥។

មេឃុំ ចៅសង្កាត់នៅក្នុងក្រុង ស្រុក ខណ្ឌនោះ ត្រូវចូលរួមក្នុងការអនុវត្តដីការបស់ក្រុង ស្រុក ខណ្ឌឲ្យមានប្រសិទ្ធភាព។ ក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងមូលដ្ឋានរបស់ខ្លួននេះផងដែរ រដ្ឋបាលក្រុង ស្រុក អាច ៖

- ដាក់បញ្ចូលសំណើគម្រោងនានាពាក់ព័ន្ធនឹងការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង ដែលឃុំ សង្កាត់បានស្នើឡើង ទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន តាមលំដាប់អាទិភាពរបស់ក្រុង ស្រុក ខណ្ឌ
- សម្របសម្រួល និងផ្តល់កិច្ចអន្តរាគមន៍ ឬណែនាំដល់មេឃុំ ចៅសង្កាត់ និងអ្នកពាក់ព័ន្ធនានា តាមរយៈយន្តការគណៈបញ្ជាការឯកភាពក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធនឹងការបង្ការ ការទប់ស្កាត់ និងការអន្តរាគមន៍ដោះស្រាយបញ្ហា ឬបទល្មើសនានា ពិសេសបទល្មើសដែលកើតឡើងពីការប្រើប្រាស់គ្រឿងស្រវឹង
- រៀបចំយុទ្ធនាការផ្សព្វផ្សាយ អប់រំកម្រិតអន្តរឃុំ សង្កាត់ នៅតាមទីប្រជុំជន ទីតាំងផ្សារ ទីតាំងស្ថាប័ន និងគ្រឹះស្ថានសាធារណៈនានា ទីតាំងសាសនា និងទីតាំងដទៃទៀតតាមការចាំបាច់
- សម្របសម្រួល អប់រំ និងទប់ស្កាត់ការផលិតជាតិស្រវឹងដែលគ្មានការអនុញ្ញាត្ត និងត្រួតពិនិត្យត្រឹមត្រូវ ការផ្សាយពាណិជ្ជកម្មពីការសេព ឬការប្រើប្រាស់គ្រឿងស្រវឹង ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ឆ្លើយតប ផ្តល់អន្តរាគមន៍ និងគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមការស្នើសុំ។

# ផ្នែកទី៣
# ដំណើរការអនុវត្តការបង្ការ
# និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង

ឃុំ សង្កាត់ជាថ្នាក់រដ្ឋបាល ដែលស្ថិតនៅកៀកទៅនឹងប្រជាពលរដ្ឋ និងបានយល់ដឹងពីបញ្ហា ផលលំបាក ការព្រួយបារម្ភ និងសុខទុក្ខរបស់ប្រជាពលរដ្ឋ ជាពិសេសបញ្ហាដែលបង្កពីការប្រើប្រាស់គ្រឿងស្រវឹង។ បញ្ហាផលលំបាកទាំងនោះ យើងបានបកស្រាយយ៉ាងច្រើនមកហើយក្នុងផ្នែកទី១នៃសៀវភៅណែនាំបច្ចេកទេសនេះ។ ក្នុងផ្នែកទី២ខាងលើ យើងបានរៀបរាប់យន្តការ និងតួនាទីសំខាន់ៗក្នុងការចូលរួមបង្ការនិងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅថ្នាក់ឃុំ សង្កាត់។ ដើម្បីឈានដល់ការចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅថ្នាក់ឃុំ សង្កាត់ឲ្យមានប្រសិទ្ធភាព រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវមានដំណើរការអនុវត្តសកម្មភាពតាមជំហានធំៗចំនួនបីគឺ ៖



## ៣.១. ការរៀបចំ និងអនុម័តដីកា

ការរៀបចំដីកាស្តីពី "ការបង្ការ និងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង" ត្រូវផ្អែកតាមនីតិវិធីនៃការរៀបចំដីកា ដូចមានកំណត់ក្នុងសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលឃុំ សង្កាត់។ លើសពីនេះទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថាដំណើរការរៀបចំដីកា ជាដំណើរការមួយមានលក្ខណៈលើកកម្ពស់ការរៀនសូត្រ បើកទូលាយ កៀរគរបានការចូលរួមពិភាក្សា និងយល់ដឹងបានច្បាស់លាស់ពីផលប៉ះពាល់ និងភាពចាំបាច់នៃការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពីសំណាក់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដូចជា ពីក្រុមស្ត្រី បុរស យុវជន កុមារ ចាស់ជរា និងពីសំណាក់អ្នកប្រកបរបរលក់គ្រឿងស្រវឹង ។

ដ្យាក្រាមខាងក្រោមនេះ គឺជាដំណើរការ នៃការរៀបចំដីកា ៖



- **ប្រជុំថ្នាក់ឃុំ សង្កាត់ ៖** ដូចបញ្ជាក់ក្នុងរូបភាពខាងលើ កិច្ចប្រជុំនៅថ្នាក់ឃុំ សង្កាត់ ក្នុងការរៀបចំ និងអនុម័តដីកាអាចមានលើសពីបីដង។ ការជួបប្រជុំលើកទី១ ដែលជាកិច្ចប្រជុំដើម្បីត្រៀមសម្រាប់កិច្ចប្រជុំនៅតាមភូមិ ឬតាមក្រុមគោលដៅក្នុងភូមិ ក្រុមប្រឹក្សាគួរចាត់អញ្ជើញគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក) តំណាងមណ្ឌលសុខភាព សាលារៀន ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អាចារ្យ តាមវត្តអារាម តំណាងយុវជនសហគមន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីពន្យល់ពីគោលបំណងនៃកិច្ចប្រជុំនៅតាមភូមិ ឬតាមក្រុមគោលដៅក្នុងភូមិ ដើម្បីកំណត់អំពីបញ្ហា និងតម្រូវការនៃការចេញដីកាព្រមទាំងស្វែងរកការគាំទ្រពីប្រជាពលរដ្ឋក្នុង ការរៀបចំដីការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់"។ ក្នុងន័យនេះផងដែរ ក្រុមប្រឹក្សាឃុំ សង្កាត់គួរស្នើសុំអ្នកចូលរួមទាំងអស់ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងផលប៉ះពាល់អវិជ្ជមានពីការប្រើប្រាស់គ្រឿងស្រវឹង ដោយអាចប្រើប្រាស់ជារូបភាព និង/ឬឧទាហរណ៍ជាក់ស្តែង ដើម្បីទាក់ទាញ និងទទួលបានការគាំទ្រពីសំណាក់ ប្រជាពលរដ្ឋក្នុងការចាត់វិធានការផ្សេងៗឈានដល់ការបង្ការកាត់បន្ថយ និងទប់ស្កាត់បាននូវការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់។

លទ្ធផលដ៏សំខាន់នៃកិច្ចប្រជុំនេះ រួមមាន ៖

- ✓ ការយល់ច្បាស់ពីផលប៉ះពាល់អវិជ្ជមានពីការប្រើប្រាស់គ្រឿងស្រវឹង
- ✓ ការយល់ច្បាស់ពីកិច្ចការដែលត្រូវធ្វើក្នុងកិច្ចប្រជុំនៅតាមភូមិ ឬតាមក្រុមគោលដៅក្នុងភូមិ ដើម្បីកំណត់ និងវិភាគអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង និងតម្រូវការនៃការចេញដីកា
- ✓ ជ្រើសរើសទីកន្លែង និងកំណត់ពេលវេលាសម្រាប់កិច្ចប្រជុំតាមភូមិ
- ✓ ជ្រើសរើស និងបែងចែកសមាជិកអង្គប្រជុំ ឬអ្នកស្ម័គ្រចិត្តសម្រាប់សម្របសម្រួល និងកត់ត្រាលទ្ធផលកិច្ចប្រជុំតាមភូមិ។ល។

- **កិច្ចប្រជុំតាមភូមិ ឬក្រុមគោលដៅ ៖** បន្ទាប់ពីកិច្ចប្រជុំលើកទី១នៅថ្នាក់ឃុំ សង្កាត់ ក្រុមតូចៗដែលត្រូវទទួលបន្ទុកក្នុងការរៀបចំកិច្ចប្រជុំនៅតាមភូមិ ឬក្រុមគោលដៅជាក់លាក់នីមួយៗត្រូវជួបប្រជុំជាមួយក្រុមប្រជាពលរដ្ឋទូទៅ និងឬក្រុមគោលដៅដែលបានកំណត់។ គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីកំណត់អំពី ស្ថានភាពនៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងភូមិ ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង និងតម្រូវការនៃការដាក់ចេញដីកា។ កិច្ចប្រជុំនេះ គួរត្រូវបានសម្របសម្រួល និងដឹកនាំដោយតំណាង គ.ក.ន.ក ឬសមាជិកក្រុមប្រឹក្សាណាម្នាក់ដែល

មានលទ្ធភាពពន្យល់ និងបកស្រាយពីបញ្ហាពាក់ព័ន្ធនឹងផលប៉ះពាល់អវិជ្ជមានពីការប្រើប្រាស់គ្រឿងស្រវឹង ដោយអាចប្រើប្រាស់ជារូបភាព និង/ឬឧទាហរណ៍ជាក់ស្តែង។

លទ្ធផលនៃកិច្ចប្រជុំទាំងនេះ គឺ ៖

- ✓ កំណត់បាននូវស្ថានភាពនៃការប្រើប្រាស់គ្រឿងស្រវឹងនៅតាមភូមិ ឬសហគមន៍នីមួយៗ
- ✓ ស្វែងយល់កាន់តែច្បាស់អំពីផលប៉ះពាល់នៃការប្រើ-ប្រាស់គ្រឿងស្រវឹង ពិសេសប៉ះពាល់ដល់ស្ត្រី និងកុមារ
- ✓ កំណត់បាននូវវិធានការនានាសម្រាប់បង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងក្នុងឃុំ សង្កាត់។

- **ប្រជុំថ្នាក់ឃុំ សង្កាត់ ៖** បន្ទាប់ពីកិច្ចប្រជុំនៅតាមភូមិនីមួយៗ ត្រូវរៀបចំកិច្ចប្រជុំលើកទី២នៅថ្នាក់ឃុំ សង្កាត់ ដើម្បីពិនិត្យ និងបូកសរុបលទ្ធផលដែលទទួលបានពីកិច្ចប្រជុំតាមភូមិនីមួយៗ។ ក្នុងករណីដែលរកឃើញថា ស្ថានភាពនៃការប្រើប្រាស់ និងផលប៉ះពាល់ពីការប្រើប្រាស់គ្រឿងស្រវឹងមានកម្រិតធ្ងន់ធ្ងរ ដែលទាមទារឲ្យមានការចាត់វិធានការ (ចេញដីកា) ដើម្បីដោះស្រាយ នោះមេឃុំ ចៅសង្កាត់ ត្រូវដាក់សំណើនៃការរៀបចំដីកានេះជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត។ ដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សា មេឃុំ ចៅសង្កាត់ត្រូវចាត់ចែងរៀបចំសេចក្តីព្រាងដីកា ដោយអនុវត្តស្របតាម

នីតិវិធីនៃការរៀបចំដីកា ដូចមានចែងក្នុងសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០៥។

លទ្ធផលដ៏សំខាន់នៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលនេះ គឺសេចក្តីព្រាងដីកាស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់" ដែលជាសេចក្តីព្រាងបឋមសម្រាប់ធ្វើការប្រឹក្សាយោបល់បន្ត។

**បទពិសោធន៍ ៖** យោងតាមបទពិសោធន៍ជាក់ស្តែងក្នុងឃុំ សង្កាត់មួយចំនួនក្នុងខេត្តស្វាយរៀង និងក្រចេះ ប្រជាជនទូទៅបានគាំទ្រការដាក់ចេញដីការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់"។

**គោលបំណង ៖** ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រី សិទ្ធិកុមារ និងបង្ការអំពើហិង្សាលើដៃគូស្និទ្ធស្នាលព្រមទាំងលើកកម្ពស់សុខុមាលភាព និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ក៏ដូចជារក្សាសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងឃុំទាំងមូល។

**វិសាលភាព ៖** ដីកានេះមានវិសាលភាពអនុវត្តទៅលើអ្នកប្រើប្រាស់គ្រឿងស្រវឹង ដែលបង្កបញ្ហា ឬបង្កការរំខាន ឬបង្កហិង្សានានារួមទាំងទៅលើអ្នកដទៃ ឬដៃគូស្និទ្ធស្នាល ព្រមទាំងអ្នកផលិតអ្នកលក់ផលិតផលគ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់។

**ខ្លឹមសារ ៖**

- ✓ ហាមប្រើ ឬលក់គ្រឿងស្រវឹងឲ្យក្មេងអាយុក្រោម...ឆ្នាំ។
- ✓ ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវពិន័យជាប្រាក់ពី...។ បើមិនរាងចាលលើកក្រោយៗត្រូវពិន័យជាប្រាក់... ។
- ✓ ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវពិន័យជាប្រាក់ពី... បើមិនរាងចាលលើកក្រោយៗត្រូវពិន័យជាប្រាក់ពី...។
- ✓ រាល់ការផលិតគ្រឿងស្រវឹងត្រូវមានការអនុញ្ញាតពីអាជ្ញាធរ ភូមិ ឃុំ និងមានការត្រួតពិនិត្យពីអ្នកជំនាញរបស់ក្រសួងសុខាភិបាល។
- ✓ អ្នកដែលប្រើប្រាស់គ្រឿងស្រវឹងហើយដើរស្រែកឡូឡា ឬ ប្រើឧបករណ៍ បំពងសំឡេងរំខានដល់អ្នកដទៃ ចាប់ពីម៉ោង ......យប់ដល់ម៉ោង...ព្រឹក ត្រូវពិន័យជាប្រាក់ពី..........។ បើមិនរាងចាលលើកក្រោយៗត្រូវផាកពិន័យជាប្រាក់ពី...។
- ✓ មិនអនុញ្ញាតអោយមានការលក់ផលិតផលគ្រឿងស្រវឹង ឬ ប្រើប្រាស់គ្រឿងស្រវឹងគ្រប់ប្រភេទនៅតាមបរិវេណវត្តអារាម សាលារៀន មណ្ឌលសុខភាពសាលាឃុំ ប៉ុស្តិ៍រដ្ឋបាល។ ជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវពិន័យជាប្រាក់ពី....។ បើមិនរាងចាលត្រូវពិន័យជាប្រាក់ពី...ដល់...។
- ✓ អ្នកពិសាគ្រឿងស្រវឹង ហើយបង្កហិង្សាដែលទាក់ទងផ្លូវកាយ ផ្លូវចិត្ត ផ្លូវសេដ្ឋកិច្ច និងផ្លូវភេទត្រូវពិន័យជាប្រាក់ពី.....ដល់.... បើមិនរាងចាលត្រូវពិន័យជាប្រាក់ពី...ដល់...។ ចំពោះបទល្មើសព្រហ្មទណ្ឌត្រូវចាត់វិធានការទៅតាមច្បាប់។
- ✓ រាល់ថវិកាដែលពិន័យបាននោះត្រូវរក្សាទុកនៅសាលាឃុំ ដើម្បីចាត់ចែងក្នុងការបើកវគ្គផ្សព្វផ្សាយពីផលប៉ះពាល់ការប្រើប្រាស់គ្រឿងស្រវឹង និងចាត់ចែងក្នុងការលើកទឹកចិត្តដល់អ្នកដែលឈប់ប្រើប្រាស់គ្រឿងស្រវឹង។

- **ការពិគ្រោះយោបល់ ៖** បន្ទាប់ពីរៀបចំសេចក្តីព្រាងដីកា ហើយ មេឃុំ ចៅសង្កាត់ត្រូវចាត់ចែងឲ្យមានកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងដីកានោះនៅតាមភូមិ ឬក្រុមគោលដៅជាក់លាក់នីមួយៗ។ គោលបំណងនៃការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នេះ គឺដើម្បីឲ្យអ្នកពាក់ព័ន្ធនានា ពិសេសប្រជាពលរដ្ឋ និងអ្នកសេពគ្រឿងស្រវឹង បានដឹង និងផ្តល់យោបល់លើសេចក្តីព្រាងដីកា ថាតើខ្លឹមសារ និងកម្រិតនៃការពិន័យដែលបានកំណត់ មានលក្ខណៈសមស្របឬទេ? អាចអនុវត្តបានឬទេ? អ្នកសេពគ្រឿងស្រវឹង គឺជាជនដែលទទួលផលប៉ះពាល់ពីការអនុវត្តដីកានេះ ដូច្នេះ ចាំបាច់ត្រូវមានការចូលរួមផ្តល់យោបល់ពីអ្នកទាំងនោះ។

| |
|---|
| លទ្ធផលដែលទទួលបានពីការពិគ្រោះយោបល់នៅតាមភូមិ គឺជាធាតុចូលសម្រាប់ពិនិត្យ និងកែសម្រួលបញ្ចប់សេចក្តីព្រាងដីកា មុនពេលដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ |

- **ប្រជុំថ្នាក់ឃុំ សង្កាត់** ដោយផ្អែកលើលទ្ធផលនៃការប្រជុំពិគ្រោះយោបល់នៅតាមភូមិ មេឃុំ ចៅសង្កាត់ត្រូវណែនាំឲ្យពិនិតលើធាតុចូលទាំងនោះ ដើម្បីកែសម្រួលបញ្ចប់សេចក្តីព្រាងដីកា។ បន្ទាប់ពីកែសម្រួលបញ្ចប់ មេឃុំរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នៅថ្នាក់ឃុំ សង្កាត់ ដើម្បីពិនិត្យ និងប្រឹក្សាយោបល់លើសេចក្តីព្រាងចុងក្រោយ

ដោយត្រូវបង្កបរិយាកាសដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន អាចចូលរួម បានស្វែងយល់ រៀនសូត្រ និងពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងដីកា។ ដូចនេះមេឃុំ ចៅសង្កាត់ចាំបាច់ត្រូវអញ្ជើញតំណាងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានឲ្យចូលរួម និងផ្តល់យោបល់លើសេចក្តីព្រាងដីកាខាងលើ។ បន្ទាប់មក មេឃុំ ចៅសង្កាត់ត្រូវដាក់ សេចក្តីព្រាងចុងក្រោយនេះទៅក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងអនុម័ត។

| |
|---|
| លទ្ធផលនៃសកម្មភាពនេះ គឺសេចក្តីព្រាងដីកាចុងក្រោយសម្រាប់ដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ |

- **ការពិនិត្យ និងអនុម័តដីកា ៖** ក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន (ប្រជុំសាមញ្ញ ឬវិសាមញ្ញ) ដើម្បីពិនិត្យ និងអនុម័តសេចក្តីព្រាងដីកាដែលបានទទួលពីមេឃុំ ចៅសង្កាត់។

| |
|---|
| លទ្ធផលចុងក្រោយនៃការពិនិត្យ និងអនុម័ត គឺដីកាស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់" ត្រូវបានអនុម័ត និងមានសុពលភាពសម្រាប់ការអនុវត្ត |

**កំណត់សម្គាល់ ៖** ការអញ្ជើញប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំទាំងនៅថ្នាក់ ភូមិ និងឃុំ ចាំបាច់ត្រូវមានការគាំទ្រជាឯកសារ រូបភាព ឧបករណ៍បំពង សម្លេង អាហារសម្រន់។ល។ យោងតាមបទពិសោធន៍នាពេលកន្លងមក កិច្ចប្រជុំទាំងនេះអាចមានអ្នកចូលរួមរហូតដល់៥០នាក់ ដែលការចំណាយសម្រាប់កិច្ចប្រជុំនីមួយៗអាចមានចន្លោះពី២០០.០០០ ដល់ ៣០០០០០រៀល (ឬ៥០ដុល្លារ ដល់៧៥ដុល្លារ)។ ក្នុងន័យនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវមានការគ្រោងថវិកា ឬវិធីសាស្រ្តក្នុងការកៀរគរថវិកា និងបច្ចេកទេសគាំទ្រពីរដ្ឋបាលស្រុក ខេត្ត ឬដៃគូអង្គការមិនមែនរដ្ឋាភិបាលនានា ដែលមានបំណងជួយជំរុញការងារ បង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនេះ។

## ៣.២. ការអនុវត្តដីកា ឬសេចក្តីសម្រេច

ការអនុវត្តដីកាស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់" ចាំបាច់ត្រូវមានសកម្មភាពយ៉ាងតិចចំនួន២ជាចម្បង៖ ទី១ គឺការបង្ការ និងទប់ស្កាត់ និងទី២ គឺការស្តារនីតិសម្បទាអ្នកញៀនគ្រឿងស្រវឹង៖

### ក) ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង

ការដាក់ចេញនូវដីកាស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់" ដែលកើតចេញពីការពិភាក្សា និងប្រឹក្សាយោបល់បែបលក្ខណៈចូលរួម គឺជាផ្នែកមួយដ៏សំខាន់ក្នុងការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់

ព្រោះថា ប្រជាពលរដ្ឋបានទទួលឱកាសស្វែងយល់ រៀនសូត្រក្នុងដំណើរការរៀបចំតាក់តែងខ្លឹមសារនៃដីកានោះរួចស្រេចមកហើយ។ ទោះជាយ៉ាងនេះក្តី ក្រុមប្រឹក្សាឃុំ សង្កាត់គួរប្រើប្រាស់វិធីសាស្ត្រ និងអនុវត្តសកម្មភាពមួយចំនួនបន្ថែមទៀត ដើម្បីទទួលបាននូវការគាំទ្រ និងចូលរួមបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់ឲ្យបានខ្លាំងខ្លា។

វិធីសាស្ត្រ និងសកម្មភាពទាំងនោះ រួមមាន ៖

- ប្រើប្រាស់យន្តការនានាដែលបានរៀបរាប់ក្នុងផ្នែកទី២នៃសៀវភៅនេះ ឬកៀរគរអ្នកស្ម័គ្រចិត្តតាមសហគមន៍ ឬជាបុគ្គលម្នាក់ៗនៅក្នុងសហគមន៍ ដើម្បីចូលរួមផ្សព្វផ្សាយអប់រំ និងធ្វើជាជនបង្គោលក្នុងការប្រមូល និងផ្តល់ព័ត៌មានរាយការណ៍ និងចូលរួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងសកម្មភាពបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់។
- រៀបចំយុទ្ធនាការផ្សព្វផ្សាយតាមរូបភាពអាន និងបិទដីកាស្តីពី "ការបង្ការ និងទប់ស្កាត់ ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់" តាមគេហដ្ឋាន ឬតាមទីតាំងដែលអាចជាគោលដៅចម្បង ដូចជា ភោជនីយដ្ឋាន ហាងលក់គ្រឿងស្រវឹង ឬទីតាំងប្រមូលផ្តុំនៃជនសេពគ្រឿងស្រវឹងនានា។ល។
- រៀបចំយុទ្ធនាការផ្សព្វផ្សាយជាទ្រង់ទ្រាយធំ ក្នុងមួយឆ្នាំយ៉ាងតិចណាស់០១ដង ដោយមានការដង្ហែរជាក្បួនតាមទីតាំងសំខាន់ៗ ដោយមានការអានដីកាឃុំ សង្កាត់ តាម

រយៈឧបករណ៍បំពងសម្លេង រៀបចំជាបដារ ពាក្យស្លោក សារ និងរូបភាពអប់រំសមស្របផ្សេងៗទៀតដែរ។

**កំណត់សម្គាល់ ៖**

- ✓ ដើម្បីធានាឲ្យការអនុវត្តបានយ៉ាងមានប្រសិទ្ធភាព ចាំបាច់ត្រូវមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយ។
- ✓ ការកៀរគរអញ្ជើញប្រជាពលរដ្ឋចូលរួម ទោះជាការធ្វើយុទ្ធនាការផ្សព្វផ្សាយតាមរូបភាពអាន និងបិទដីកាស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់" ឬដង្ហែរជាក្បួនតាមទីតាំងសំខាន់ៗ គឺសុទ្ធតែចាំបាច់ត្រូវមានការចំណាយលើអាហារសម្រន់ ប្រេងសាំង ឬសោហ៊ុយធ្វើដំណើរ ការផលិតបដារ ពាក្យស្លោក សារ និងរូបភាពអប់រំ ឧបករណ៍បំពងសម្លេង។ល។
- ✓ យោងតាមបទពិសោធន៍នាពេលកន្លងមក ការធ្វើយុទ្ធនាការផ្សព្វផ្សាយ តាមរូបភាពអាន និងបិទដីកាតាមផ្ទះ ដោយប្រើប្រាស់អ្នកស្ម័គ្រចិត្ត អាចផ្តល់ជាថវិកា១០០០០រៀល សម្រាប់អាហារសម្រ៉ន់ និងការធ្វើដំណើរក្នុងមួយថ្ងៃ។
- ✓ សម្រាប់ដង្ហែរជាក្បួនតាមទីតាំងសំខាន់ៗនានា ការចំណាយលើឧបករណ៍បំពងសម្លេង ការរៀបជាបដារ ពាក្យស្លោក រូបភាព អាវ មួក មានសារអប់រំ អាហារសម្រន់។ល។

- ✓ ទោះជាការចំណាយអាចមានទំហំធំក្តី ក្រុមប្រឹក្សាឃុំ សង្កាត់ ចាំបាច់ត្រូវទទួលស្គាល់ថា លទ្ធផលដែលទទួលបានពីការកាត់បន្ថយលើការសេពគ្រឿងស្រវឹង ដែលជាកត្តាចម្បង ក្នុងការប្រព្រឹត្តិអំពើហិង្សា អសន្តិសុខសង្គម គ្រោះថ្នាក់ចរាចរ អំពើអបាយមុខ និងអំពើខុសច្បាប់នានា បញ្ហាសុខភាព និងជាពិសេសភាពក្រីក្រ គឺជាអ្វីដែលមិនអាចកាត់ថ្លៃបាន។
- ✓ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏គួរប្រឹងប្រែងកៀរគរថវិកា និងការគាំទ្របច្ចេកទេស ពីរដ្ឋបាលស្រុក ខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ឬសប្បុរសជន ដែលមានបំណងជួយជំរុញការងារបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនេះផងដែរ។

### ខ) ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងស្រវឹង

ការស្តារនីតិសម្បទានអ្នកញៀនគ្រឿងស្រវឹង ក៏ជាផ្នែកមួយដ៏សំខាន់ក្នុងការអភិវឌ្ឍសហគមន៍ផងដែរ។ សកម្មភាពមួយចំនួនដែលក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តបានរួមមាន ៖

- កំណត់មុខសញ្ញាអ្នកញៀន និងបំពានគ្រឿងស្រវឹងតាមរយៈស្នើសុំដល់អ្នកស្ម័គ្រចិត្ត ឬប្រធានភូមិផ្តល់ព័ត៌មាន និងរបាយការណ៍ប្រចាំខែ
- ស្នើសុំការគាំទ្រពីស្ថាប័នជំនាញ ឬជ្រើសរើសអ្នកស្ម័គ្រចិត្ត ដែលមានការអប់រំ និងចំណេះដឹងសមស្រប ដើម្បី

ចូលរួមក្នុងវគ្គសិក្សាជំនាញ ផ្តល់ប្រឹក្សាយោបល់ជាមួយ បុគ្គលញៀន ឬបំពានគ្រឿងស្រវឹង

- សម្របសម្រួល និងរៀបចំកម្មវិធីសម្រាប់ការផ្តល់សេវាប្រឹក្សាយោបល់ ក្នុងករណីទទួលបានការគាំទ្រពីអ្នកជំនាញប្រឹក្សាយោបល់ជាមួយ បុគ្គលញៀន ឬបំពានគ្រឿងស្រវឹង។

**កំណត់សម្គាល់៖** អង្គការមូលនិធិអាស៊ី (TAF) និងអង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO) បានផលិតឯកសារស្តីពីគោលការណ៍ណែនាំក្នុងការប្រឹក្សាយោបល់ និងមានអ្នកជំនាញក្នុងការបង្រៀនដល់អ្នកស្ម័គ្រចិត្ត ឬបុគ្គលដែលអាចជួយកិច្ចការនេះដល់ក្រុមប្រឹក្សាឃុំ សង្កាត់។

# ផ្នែកទី៤
# ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ៤.១. នៅថ្នាក់ឃុំ សង្កាត់

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តដីកាស្តីពី "ការបង្ការ និងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង" មានទិដ្ឋភាព និងសកម្មភាពដូចគ្នាទៅនឹងការតាមដាន ត្រួតពិនិត្យ និងវាយតំលៃគម្រោងឃុំ សង្កាត់ផ្សេងទៀតផងដែរ ហើយដែលមានរៀបរាប់លំអិតក្នុងសៀវភៅស្តីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោងអភិវឌ្ឍន៍កិច្ចការរដ្ឋបាល និងកិច្ចការហិរញ្ញវត្ថុឃុំ សង្កាត់ ឆ្នាំ២០០៩។ សកម្មភាពសំខាន់ៗមួយចំនួនក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តដីកាស្តីពី "ការបង្ការ និងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង" រួមមាន ៖

### ក) ការតាមដាន ត្រួតពិនិត្យ

ការតាមដាន ការត្រួតពិនិត្យលើគម្រោងឃុំ សង្កាត់ត្រូវចាប់ផ្តើមពីការប្រមូលព័ត៌មាន។ សម្រាប់ការងារតាមដានការអនុវត្តដីកាស្តីពី "ការបង្ការ និងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង" ក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវស្នើសុំដល់អ្នកស្ម័គ្រចិត្ត តាមរយៈប្រធានភូមិ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព និង គ.ក.ន.ក. ដើម្បីប្រមូល និងធ្វើបច្ចុប្បន្នភាពព័ត៌មានប្រចាំខែ ឬត្រីមាសស្តីពី ៖

- ចំនួនទីតាំងផលិតគ្រឿងស្រវឹងនៅមូលដ្ឋាន
- ចំនួនស្តង់លក់គ្រឿងស្រវឹង
- ចំនួនស្តង់ដែលមានយុវជន ឬកុមារដែលស្ថិតក្នុងកម្រិតអាយុហាមឃាត់ចូលរួមលក់គ្រឿងស្រវឹង
- ចំនួនស្តង់ដែលអនុញ្ញាតដល់យុវជន ឬកុមារដែលស្ថិតក្នុងកំរិតអាយុហាមឃាត់ក្នុងការទិញគ្រឿងស្រវឹង
- ចំនួនអ្នកញៀន និងបំពានគ្រឿងស្រវឹង
- ចំនួនយុវជន ឬកុមារដែលចូលរួមលក់គ្រឿងស្រវឹង
- ចំនួនយុវជន ឬកុមារដែលទិញគ្រឿងស្រវឹង
- ចំនួនយុវជន ឬកុមារដែលសេពគ្រឿងស្រវឹង
- ចំនួនអំពើហិង្សា ករណីអសន្តិសុខ ករណីគ្រោះថ្នាក់ចរាចរណ៍ អំពើអបាយមុខ និងខុសច្បាប់នានាដែលបង្កដោយការសេពគ្រឿងស្រវឹង ក្នុងមូលដ្ឋាន

## តារាងព័ត៌មាន(សូចនាករ)

## ដើមគ្រាមុនពេលអនុវត្តដីកា

**ឈ្មោះឃុំ៖.............** **កាលបរិច្ឆេទ៖...................**

| ល.រ | សូចនាករ | ចំនួនករណីតាមភូមិ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ភូមិ១ | ២ | ៣ | ៤ | ៥ | |
| ១ | ទីតាំងផលិតគ្រឿងស្រវឹង | | | | | | |
| ២ | ស្តង់លក់គ្រឿងស្រវឹង | | | | | | |
| ៣ | ស្តង់ដែលមានយុវជន ឬកុមារ ចូលរួមលក់គ្រឿងស្រវឹង | | | | | | |

| ល.រ | សូចនាករ | ចំនួនករណីតាមភូមិ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ភូមិ១ | ២ | ៣ | ៤ | ៥ | |
| ៤ | ស្តង់ដែលមានយុវជន ឬ កុមារទិញគ្រឿងស្រវឹង | | | | | | |
| ៥ | អ្នកញៀន និងបំពានគ្រឿងស្រវឹង | | | | | | |
| ៦ | យុវជន ឬកុមារដែលចូលរួមលក់គ្រឿងស្រវឹង | | | | | | |
| ៧ | យុវជន ឬ កុមារដែលលក់គ្រឿងស្រវឹង | | | | | | |
| ៨ | យុវជន ឬ កុមារដែលសេពគ្រឿងស្រវឹង | | | | | | |
| ៩ | អំពើហិង្សាបង្ក ដោយការសេពគ្រឿងស្រវឹង | | | | | | |
| ១០ | ករណីអសន្តិសុខដែលបង្កដោយការសេពគ្រឿងស្រវឹង | | | | | | |
| ១១ | ករណីគ្រោះថ្នាក់ចរាចរដែលកើតដោយការសេពគ្រឿងស្រវឹង | | | | | | |
| ១២ | អំពើអបាយមុខ និងខុសច្បាប់នានាដែលបង្កដោយការសេពគ្រឿងស្រវឹង | | | | | | |

# តារាងតាមដានព័ត៌មាន(សូចនាករ)
# ក្នុងពេលអនុវត្តដីកា (ប្រចាំខែ/ ត្រីមាស)

**ឈ្មោះឃុំ៖.......** **កាលបរិច្ឆេទ៖....................**

| ល.រ | សូចនាករ | ចំនួនករណីតាមភូមិ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ភូមិ១ | ២ | ៣ | ៤ | ៥ | |
| ១ | ទីតាំងផលិតគ្រឿងស្រវឹង | | | | | | |
| ២ | ស្តង់លក់គ្រឿងស្រវឹង | | | | | | |
| ៣ | ស្តង់ដែលមានយុវជន ឬ កុមារ ចូលរួមលក់គ្រឿងស្រវឹង | | | | | | |
| ៤ | ស្តង់ដែលមានយុវជន ឬ កុមារទិញគ្រឿងស្រវឹង | | | | | | |
| ៥ | អ្នកញៀន និងអ្នកបំពានគ្រឿងស្រវឹង | | | | | | |
| ៦ | យុវជន ឬកុមារដែលចូលរួមលក់ គ្រឿងស្រវឹង | | | | | | |
| ៧ | យុវជន ឬ កុមារដែលទិញគ្រឿងស្រវឹង | | | | | | |
| ៨ | យុវជន ឬ កុមារដែលសេពគ្រឿងស្រវឹង | | | | | | |
| ៩ | អំពើហិង្សាបង្កដោយការសេពគ្រឿងស្រវឹង | | | | | | |
| ១០ | ករណីអសន្តិសុខដែលបង្កដោយការសេពគ្រឿងស្រវឹង | | | | | | |

| លរ | សូចនាករ | ចំនួនករណីតាមភូមិ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ភូមិ១ | ២ | ៣ | ៤ | ៥ | |
| ១១ | ករណីគ្រោះថ្នាក់ចរាចរដែលកើតដោយការសេពគ្រឿងស្រវឹង | | | | | | |
| ១២ | អំពើអបាយមុខ និងខុសច្បាប់នានាដែលបង្កដោយការសេពគ្រឿងស្រវឹង | | | | | | |

ការទទួលបានរបាយការណ៍របៀបនេះជាប្រចាំ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចនឹងធ្វើការប្រៀបធៀបទៅលើការអនុវត្តដីកាស្ដីពី "ការបង្ការ និងទប់ស្កាត់ អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងស្រវឹង" និងចាត់វិធានការបន្ថែម ក្នុងករណីអំពើហិង្សា ករណីអសន្តិសុខ ករណីគ្រោះថ្នាក់ចរាចរណ៍ អំពើអបាយមុខ និង អំពើខុសច្បាប់នានា ដែលបង្កដោយការសេពគ្រឿងស្រវឹងក្នុងមូលដ្ឋាន មិនទាន់មានការថយចុះសមស្រប។

វិធីសាស្ត្រតាមដាន ត្រួតពិនិត្យមួយចំនួនបន្ថែមទៀត គឺក្រុមប្រឹក្សាឃុំ សង្កាត់ អាចជ្រើសរើសយុវជន ឬកុមារក្នុងមូលដ្ឋាន ដើម្បីប្រើជាធ្នាក់ ក្នុងការសាកល្បងទិញគ្រឿងស្រវឹងតាមស្ដង់នានា ដើម្បីបញ្ជាក់ថាស្ដង់ទាំងនោះប្រាកដជាគោរពតាមដីកាស្ដីពី "ការបង្ការ និងទប់ស្កាត់អំពើហិង្សា រួមទាំងគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងស្រវឹង" និងបែងចែកភារកិច្ច ឬប្រគល់ភារកិច្ចដល់អ្នកស្ម័គ្រចិត្ត តាមរយៈប្រធានភូមិ ប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ សាលារៀន មណ្ឌលសុខភាព និង គ.ក.ន.ក. ក្នុងការតាមដានការប្រើប្រាស់គ្រឿងស្រវឹងក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាប្រចាំផងដែរ។

**កំណត់សម្គាល់ ៖**

- ✓ យន្តការតាមដាន ត្រួតពិនិត្យមួយដែលមិនតម្រូវឲ្យមានការចំណាយច្រើន គឺការប្រើប្រាស់ ឬភ្ជាប់វេទិកាស្តីពីការអនុវត្តវិធានការភូមិ ឃុំមានសុវត្ថិភាពជាមួយនឹងរបបរាយការណ៍ ស្តីពីករណីទាំងអស់ខាងលើ។
- ✓ ការដោះស្រាយបញ្ហាបុគ្គល ទោះជាក្នុងករណីប្រជាពលរដ្ឋ ឬអាជីវករ មិនទាន់ចូលរួមអនុវត្តដីកាស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់" ក្រុមប្រឹក្សាចាំបាច់ត្រូវសហការណ៍ជាមួយប៉ូលីសក្នុងឃុំ សង្កាត់ និង/ឬ អាចរាយការណ៍សុំការគាំទ្រនានាពីរដ្ឋបាលស្រុកផងដែរ។

**ខ) ការវាយតម្លៃ**

ការវាយតម្លៃស្នាដៃភូមិ ឃុំមានសុវត្ថិភាព គ្មាន ឬកាត់បន្ថយបាននូវអំពើហិង្សា ករណីអសន្តិសុខ ករណីគ្រោះថ្នាក់ចរាចរណ៍ អំពើអបាយមុខ និងអំពើខុសច្បាប់នានាគឺជាផ្នែកមួយដ៏សំខាន់ក្នុងការវាយតំលៃ ថាតើការអនុវត្តដីកាស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងឃុំ សង្កាត់" ទទួលបានជោគជ័យ ឬយ៉ាងណា។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវធ្វើការបូកសរុបរបាយការណ៍ ឬព័ត៌មានប្រចាំខែ ឬត្រីមាសស្តីពីករណីហិង្សា ករណីអសន្តិសុខ ករណីគ្រោះថ្នាក់ចរាចរណ៍ អំពើអបាយមុខ និងអំពើខុសច្បាប់នានា។ ក្នុងការអនុវត្តការងារសរុបរបាយការណ៍ផងដែរ ក្រុមប្រឹក្សាឃុំ សង្កាត់អាចស្នើសុំដល់អង្គភាព និងស្ថាប័នពាក់ព័ន្ធ ដូចជាប៉ុស្តិ៍នគរ បាលរដ្ឋបាលឃុំ សង្កាត់ផ្តល់នូវរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំផងដែរ។

# ទម្រង់ព័ត៌មាន(សូចនាករ)

# ពាក់ព័ន្ធផ្តល់ដោយប៉ុស្តិ៍នគរបាលរដ្ឋបាល

**ឈ្មោះឃុំ៖.......** **កាលបរិច្ឆេទ៖...................**

ផ្តល់ដោយ៖.......................................

| ល.រ | សូចនាករ | ចំនួនករណីតាមភូមិ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ភូមិ១ | ២ | ៣ | ៤ | ៥ | |
| ១ | អំពើហិង្សាបង្ក ដោយការសេពគ្រឿងស្រវឹង | | | | | | |
| ២ | ករណីអសន្តិសុខដោយការសេពគ្រឿងស្រវឹង | | | | | | |
| ៣ | ករណីគ្រោះថ្នាក់ចរាចរដោយការសេពគ្រឿងស្រវឹង | | | | | | |
| ៤ | អំពើអបាយមុខ និង អំពើខុស ច្បាប់ដោយការសេពគ្រឿង ស្រវឹង | | | | | | |

ក្រោយពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការវិភាគ បូកសរុប និងរៀបចំជារបាយការណ៍ស្តីពីលទ្ធភាពនៃការអនុវត្តដីកាស្តីពី "ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង នៅក្នុងឃុំ សង្កាត់" ផ្ញើជូនដល់រដ្ឋបាលស្រុក និងចាំបាច់ត្រូវផ្សព្វផ្សាយ នូវលទ្ធផលទាំងនេះ ដល់ប្រជាពលរដ្ឋទូទៅរៀងរាល់ឆ្នាំផងដែរ។

## ៤.២. នៅថ្នាក់ក្រុង ស្រុក ខណ្ឌ

ក្រៅពីតួនាទីដែលមានរៀបរាប់ក្នុងផ្នែក២.២. រដ្ឋបាលក្រុង ស្រុក ខណ្ឌក៏អាចអនុវត្តនូវអ្វីដែលរដ្ឋបាលឃុំ សង្កាត់ អាចធ្វើបានផងដែរ (ឧទាហរណ៍រដ្ឋបាលក្រុង ស្រុក ខណ្ឌអាចចេញជាដីកា និងសេចក្តីសម្រេចដូចគ្នានេះក្នុងការបង្ការ និងទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងក្នុងដែនសមត្ថកិច្ចក្រុង ស្រុក ខណ្ឌរបស់ខ្លួនផងដែរ)។ ក្នុងករណីរដ្ឋបាលក្រុង ស្រុក ខណ្ឌ អនុវត្តកិច្ចការនេះដូចគ្នានឹងឃុំ សង្កាត់ ការតាមដានវាយតម្លៃលើការអនុវត្ត ក៏មានប្រហាក់ប្រហែលនឹងអ្វីដែលបានរៀបរាប់សម្រាប់ឃុំ សង្កាត់ខាងលើ។

ទោះជារដ្ឋបាលក្រុង ស្រុក ខណ្ឌមិនអនុវត្តផ្ទាល់ ក្រុង ស្រុក ខណ្ឌ ក៏ជាយន្តការវាយតម្លៃមួយទៀត ដែលអាចចាត់ទុកថា ជាយន្តការវាយតម្លៃផ្ទៃក្រៅទៅលើការអនុវត្តរបស់រដ្ឋបាលឃុំសង្កាត់ ក្នុងដែនសមត្ថកិច្ចក្រុង ស្រុក ខណ្ឌរបស់ខ្លួន។ កិច្ចការវាយតម្លៃនេះក៏មិនមានជាបញ្ហាថ្មីនោះទេ ដូចជាកន្លងមក រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត បានបង្កើតកម្មវិធីប្រឡងប្រណាំងភូមិ ឃុំ មានសុវត្ថិភាពរួចមកហើយ។

ផ្អែកតាមប្រសិទ្ធភាពនៃកម្មវិធីប្រឡងប្រណាំងភូមិ ឃុំមានសុវត្ថិភាព រដ្ឋបាលក្រុង ស្រុក ខណ្ឌ គួរប្រើប្រាស់វិធីសាស្ត្រជំរុញដូចគ្នានេះ ដោយបន្ថែមកម្មវិធីប្រឡងប្រណាំងភូមិ ឃុំមានការសេពគ្រឿងស្រវឹងទាប ឬគ្មានសោះ និងផ្តល់ជាប័ណ្ណសរសើរ មេដាយ និងរង្វាន់លើកទឹកចិត្តដល់រដ្ឋបាលឃុំ សង្កាត់ និងអាជ្ញាធរភូមិដែលមានស្នាដៃល្អប្រសើរផងដែរ។